## PeoplePoint

## សានទៅរកផលប្រយោជន៍

កម្មវិធីនេះផ្តល់នូវការទាក់ទងដល់ផលប្រយោជន៍សំខាន់ៗផ្សេងទៀត។

- **ការថែទាំកុមារ:** ជួយគ្រួសារស្វែងរក និងបង់ថ្លៃសំរាប់ការថែទាំកុមារដែលមានគុណភាពសំរាប់កុមារអាយុក្រោម 13 ឆ្នាំ។
- **ការថែទាំសុខភាព:** ជួយគ្រួសារស្វែងរក និងបុគ្គលឲ្យទទួលបាននូវការថែទាំសុខភាពដោយមិនគិតថ្លៃឬតំលៃទាបសំរាប់កុមារ និង មនុស្សពេញវ័យ។
- **ជំនួយម្ហូបអាហារ:** ជួយគ្រួសារដោយផ្តល់នូវម្ហូបអាហារដែលមានសារជាតិបំប៉នរាងកាយគ្រប់គ្រាន់ និងមានតុល្យភាព។
- **ចំណូលផ្នែកបង់ពន្ធ:** ជួយធ្វើការរៀបចំឲ្យបង់ពន្ធ ដោយមិនគិតថ្លៃ និងបង់តាមអេឡិចត្រូនិច (206) 315-8722 ។

សំរាប់ព័ត៏មានបន្ថែម, ទូរស័ព្ទទៅ **(206) 684-0355**។

## ការិយាល័យអភិបាលក្រុងសំរាប់ប្រជាពលរដ្ឋវ័យចំណាស់

ការិយាល័យអភិបាលក្រុងសំរាប់ប្រជាពលរដ្ឋវ័យចំណាស់ (Mayor’s Office for Senior Citizens) ជួយពង្រឹង ជីវិតជនចំណាស់ដោយ គ្រប់គ្រងជំនួយផ្សេងៗ, ការងារ, និងកម្មវិធីស្ម័គ្រចិត្ត, និង អាចធ្វើទំនាក់ទំនងរវាងជនវ័យចំណាស និងក្រុមគ្រួសាររបស់ ពួកគេទៅនឹងធនធាន ការរស់នៅដែលទ្រទ្រង់វ័យចំណាស់ដែលមានសុខភាពល្អ, សហគមន៍ជាច្រើនដោយឯករាជ្យ, និង ទំនាក់ទំនងរវាងសង្គមនិង ស៊ីវិល។

**សំរាប់ព័ត៏មានបន្ថែម, ទូរស័ព្ទទៅ (206) 684-0500**។

## Mayor’s Office for Senior Citizens


810 - 3rd Avenue, Suite 350
(The Central Building)
Seattle, WA 98104

ថ្ងៃច័ន្ទ - សុក្រ
8:00 a.m. – 5:00 p.m.

TEL (206) 684-0500
FAX (206) 684-0494
TTY/TDD (206) 233-2778

អ៊ិនធើណែត
**www.seattle.gov/humanservices/mosc/**


ការិយាល័យអភិបាលក្រុងសំរាប់ប្រជាពលរដ្ឋវ័យចំណាស់ (Mayor’s Office for Senior Citizens) គ្រប់គ្រងដោយក្រសួងសេវាកម្មធនធានមនុស្សក្រុងស៊ីអាថុល (Seattle Human Services Department) អនុវត្តទៅតាមច្បាប់រើសអើងនៃសហព័ន្ធ, រដ្ឋ, និងតំបន់។

ការស្នាក់នៅសំរាប់មនុស្សពិការនឹងផ្តល់តាមការស្នើសុំ។

**Gregory J. Nickels, អភិបាលក្រុង ទីក្រុង Seattle**

**Patricia McInturff, ប្រធាន**
**Seattle Human Services Department**

**Irene Stewart, ប្រធាន**
**Mayor’s Office for Senior Citizens**

# កម្មវិធីជំនួយផ្នែក ថាមពល និង ទឹកភ្លើង



City of Seattle
Human Services Department
Gregory J. Nickels, Mayor

# កម្មវិធីជំនួយផ្នែកទឹកភ្លើង

*ផ្តល់នូវជំនួយទឹកភ្លើងផ្សេងៗ ដល់ក្រុមគ្រួសារដែលមានសិទ្ធិ ដែលផ្តល់ដោយ Seattle City Light និង Seattle Public Utilities*



## ជំនួយខាងបង់លុយកាក់

ពេលដែលទឹកភ្លើងឡើងថ្លៃ, វាមិនមែនតែងតែជាការងាយស្រួលសំរាប់មនុស្សក្នុងការបង់នោះទេ។ មានកម្មវិធីជាច្រើនអាចជួយឲ្យអ្នកបង់ថ្លៃជំពាក់ ហើយនូវតែអាចបង់ទឹកភ្លើងឲ្យទាន់ពេលវេលាទៀត។ ការិតប្រាក់ចំណូលផ្សេងៗត្រូវគេអនុវត្ត។ **អ្នកអាចមានសិទ្ធទទួលកម្មវិធីច្រើនជាងមួយ។**

## កម្មវិធីជំនួយប្រាក់ចំណូលលើផ្នែកថាមពលគេហដ្ឋាន (LIHEAP)

បើសិនជាអ្នកមិនអាចបង់វិក័យប័ត្រផ្នែកថាមពលគេហដ្ឋានរបស់អ្នកបាន ហើយប្រឈមមុខនឹងការរស់នៅ ដោយគ្មានកំដៅនៅក្នុងផ្ទះ អ្នកអាចត្រូវប្រថុយនឹងការកើតមានជម្ងឺឬការរងទុក្ខនានា។ LIHEAP គឺជា កម្មវិធីដែលទទួលប្រាក់មកពីសហព័ន្ធ ដើម្បីជួយដល់ម្ចាស់ផ្ទះនិងអ្នកជួលផ្ទះទាំងឡាយដែលមានប្រាក់ចំណូលតិច ដែលមានលក្ខណសម្បត្តិទទួលជំនួយ ឲ្យជួបតាមសេចក្តីត្រូវការនៃកំដៅនិង ឬភាពត្រជាក់នៅក្នុងគេហដ្ឋានរបស់ពួកគេ។ អ្នកមិនចាំបាច់ត្រូវតែមានលិខិតជូនដំណឹងនៃការកាត់ទឹកភ្លើងឬទូរស័ព្ទ ទើបទទួល ជំនួយបាននោះទេ។

**ដើម្បីទទួលជំនួយ ចូរទូរស័ព្ទ 1-8030-348-7144 ។**

## កម្មវិធី ELIA

Seattle City Light ផ្តល់នូវជំនួយអ្នកមានប្រាក់ចំណូលទាបដែល បន្ទាន (ELIA) ដល់អតិថិជនដែលមានសិទ្ធិ ដែលប្រឈមមុខនឹងការកាត់ផ្តាច់ភ្លើង។ ELIA នឹងមានបន្ទាប់ពីកម្មវិធី EAP ដែលផ្តល់មូលនិធិដោយសហព័ន្ធ ត្រូវបានប្រើប្រាស់រួចហើយ ឬក៏មិនមានសំរាប់ប្រើប្រាស់តទៅទៀត។ **សំរាប់ព័ត៏មានបន្ថែម, ទុរស័ព្ទទៅ (206) 684-3688 ។**

## ការចុះតំលៃទឹកភ្លើង

កម្មវិធីនេះផ្តល់នូវការបញ្ចុះតំលៃទឹកភ្លើង សំរាប់គ្រួសារដែលពេញសិទ្ធិខាងប្រាក់ចំណូល, មនុស្សចាស់ (អាយុលើសពី 65), និងមនុសដែលមានពិការភាព។ អ្នកដាក់ពាក្យដែលមានសិទ្ធទទួលការចុះតំលៃ50ភាគរយ នៅក្នុងវិក័យប័ត្រភ្លើងSeattle City Light។ អ្នកដែលជាអ្នករស់នៅក្រុងស៊ីអាថុល អាចទទួលការចុះតំលៃនៅក្នុងវិក័យប័ត្រSeattle Public Utilities សរុប (ទឹក, ទឹកស្អុយ, និងសំរាម)។

អ្នកដាក់ពាក្យសុំត្រូវតែជួបនឹងត្រូវការចំបងបីៈ

- ក្រុមគ្រួសារត្រូវតែជួបនឹងការិតប្រាក់ចំណូល។
- អ្នកដាក់ពាក្យសុំអាចនឹងមិនមែនជាអ្នករស់នៅក្នុងផ្ទះដែលជួយដោយសហព័ន្ធ (Section 8, Seattle Housing Authority, King County Housing Authority, HUD, Shelter+Care, ។ល។), លើកលែងតែផ្ទះល្វែងSHA Bond
- វិក័យប័ត្រSeattle City Light ត្រូវតែនៅក្នុងឈ្មោះរបស់អ្នកដាក់ពាក្យសុំ។

**សំរាប់ព័ត៏មានបន្ថែម, ទូរស័ព្ទទៅ (206) 684-0268 ។**

## គំរោង Share

គំរោង Share ផ្តល់នូវជំនួយបង់ថ្លៃ និងការប្រឹក្សាសំរាប់អតិថិជន Seattle City Light ដែលមានសិទ្ធ ដែលប្រឈមនឹងការកាត់ផ្តាច់ សេវាភ្លើង។ ជំនួយគំរោង Share ខុសផ្លែកគ្នាទៅតាម កាលៈទេសៈផ្សេងៗ។ ក្រុមគ្រួសារត្រូវជួបនូវការិតប្រាក់ចំណូល, ហើយវិក័យប័ត្រ Seattle City Light ត្រូវតែនៅក្នុងឈ្មោះរបស់អ្នកដាក់ពាក្យ។ អតិថិជន ត្រូវតែធ្វើការរៀបចំការបង់ប្រាក់ជាមួយ ហើយនិងណែនាំដោយ Seattle City Light ។ **សំរាប់ព័ត៏មានបន្ថែម, ទូរស័ព្ទទៅ (206) 684-3000 ។**

## កម្មវិធីជំនួយបន្ទាន់អាសន្ននៃ SPU

អតិថិជនSeattle Public Utilities នៅក្នុងគ្រួសារតែមួយ ដែលមិនទាន់បង់ថ្លៃទឹកតាមការកំណត់ និងប្រឈមមុខនឹងការកាត់ផ្តាច់ទឹក, ទឹកស្អុយ, និងសំរាម អាចមានលក្ខណសម្បត្តិសំរាប់ជំនួយបង់ជូនក្នុងភាពបន្ទាន់អាសន្ន។ ក្រុមគ្រួសារត្រូវតែជយបតាមគោលការណ៍ប្រាក់ចំណូល។ វិក័យប័ត្រSeattle Public Utilities ត្រូវតែនៅក្នុងឈ្មោះអ្នកដាក់ពាក្យសុំ។ **សំរាប់ព័ត៏មានបន្ថែម, ទូរស័ព្ទទៅ (206) 684-5800 ។**

## ការការពារផ្ទះពីអាកាសធាត

ការិយាល័យផ្ទះ (Office of Housing) នៃក្រុងស៊ីអាថុល ផ្តល់ការការពារផ្ទះពីអាកាសធាតុសំរាប់ម្ចាស់ផ្ទះ ដែលមានប្រាក់ចំណូលពេញសិទ្ធិ និងអ្នកជួលផ្ទះ (គ្រួសារម្នាក់ឯង និងផ្ទះល្វែង)។ សេវាផ្សេងទៀត រួមបញ្ចូលការឲ្យខ្ចីឲ្យជួសជុលផ្ទះ ដោយយកការប្រាក់ថោកដល់ម្ចាស់ផ្ទះដែលកំពុងរស់នៅ, ផ្ទះដែលមានគ្រួសារតែមួយ ហើយមានប្រាក់ចំណូលទាបដល់មធ្យម។ **សំរាប់ព័ត៏មានបន្ថែម, ទូរស័ព្ទទៅ (206) 684-0244 ។**